# កែវភ្នែកអ្នកសុំទាន

ពាក្យ៨

ភ្នែកខ្ញុំមើលដីឃើញដីពាសវាល
អើតមើលអាគារគិតលានអស់ពាន់
បន្ទប់រាប់ម៉ឺនកំពស់រយជាន់
តែទាស់មិនគ្រាន់មិនសល់ខ្ញុំដេក។
សាច់ជ្រូកមាន់ទាគោនិងក្របី
ផ្សារពេញផែនដីដាក់តាំងស្កុះស្អេក
សត្វស្លាប់រាប់លានបំពេញមនុស្សស្រែក
ឱសែនសង្វេកមិនសល់ខ្ញុំស៊ី។
ថ្នាំញៀនស្រីល្បែងសង្គមថាស្អប់
ស្អប់អើយសែនស្អប់ៗគ្រប់ទិសទី
តែគេបោះលុយប្រញ៉ាយរកស៊ី
ដាក់មួយថែមពីរបានខ្ពស់មុខទៀត។
មនុស្សគ្រប់រូបស្រលាញ់អ្នកក្រ
គេនិយាយតម្តងហើយម្តងទៀត
និយាយមិនខ្ជិលឲ្យតែជួបញាតិ
តែទាស់ខ្ញុំបៀតមិនជួយហើយដេរ។

ភ្នំពេញ ២២ មេសា ២០០៨
សួយ ឡូយ